# លក្ខណៈសកលនៅក្នុងរឿងទុំទាវ

## ១.សេចក្ដីផ្ដើម ៖

បច្ចុប្បន្នប្រទេសជាតិមានការរីកចម្រើនក្នុងដំណាក់កាលមួយគួឲ្យចាប់អារម្មណ៍។រីឯអក្សរសិល្ប៍វិញក៏មានការរីកចម្រើនគួរឲ្យកត់សម្គាល់ផងដែរ។សព្វថ្ងៃនេះមានអ្នកនិពន្ធជាច្រើនបានបញ្ចេញស្នាដៃរបស់ខ្លួន ដើម្បីទាក់ទាញអារម្មណ៍អ្នកអាន អ្នកស្ដាប់ អ្នកស្ដាប់ អ្នកទស្សនាឲ្យជក់ចិត្ត ជិតអារម្មណ៍ ទៅលើកម្រងអត្ថបទនីមួយៗ ។ ស្នាដៃរបស់ពួកគេបានបង្កប់នូវខ្លឹមសារអប់រំ តាមគោលបំណងរបស់បុគ្គលនីមួយៗ ដែលជាការនិយមរបស់មនុស្សទូទៅ។ ដោយឡែកអ្នកនិពន្ធ **ភិក្ខុ សោម** វិញថ្វីត្បិតតែលោកជាព្រះសង្ឃក៏ពិតមែន តែស្នាដៃលោកមិនចាញ់ស្នាដៃសម័យថ្មីនេះឡើយហើយពិសេសគឺ **រឿងទុំទាវ** ។ រឿងទុំទាវនេះ ជាស្នាដៃមួយដ៏មានតម្លៃក្នុងខឿនអក្សរសិល្ប៍ជាតិ មិនតែប៉ុណ្ណោះស្នាដៃមួយនេះបានល្បីល្បាញនៅភូមិភាគអាស៊ីអាគ្នេយ៍យើងនេះ។ រឿងនេះ **ភិក្ខុ សោម** បានពន្លេចនូវស្មារតីមនុស្សនិយម ជាហេតុធ្វើឲ្យមានការនិយមចូលចិត្តពីគ្រប់មជ្ឈដ្ឋាន។ ម្យ៉ាងទៀតលោកបានបង្ហាញពីលក្ខណៈទូទៅគ្រប់ស្រទាប់វណ្ណៈ ទាំងពីថ្នាក់លើរហូតដល់ថ្នាក់ក្រោម (ស្ដេច មន្ត្រី រាស្ត្រ)ដោយមិនប្រកាន់និន្នាការអ្វីមួយឡើយ។ ហេតុនេះហើយទើបអ្នកសិក្សាជាច្រើនបានឲ្យតម្លៃរឿងនេះថាគឺពិតជាមានតម្លៃពិសេសរបស់ខ្លួនក្នុងខឿនវប្បធម៌ជាតិ លើសពីរឿងផ្សេងៗ ក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរ ហើយប្រជាជនភាគច្រើនចេះចាំរឿងទុំទាវហើយបានចាត់ទុករឿងនេះជាមរតកសិល្បៈមួយដែលមិនអាចខ្វះបានក្នុងជីវភាពប្រចាំថ្ងៃរបស់ខ្លួន។

## ២.អត្ថន័យទូទៅនៃពាក្យ«សកល» ៖

តាមវចនានុក្រមរបស់សម្ដេចសង្ឃរាជ ជួន ណាតពាក្យ«សកល»ឬ«សាកល» មានន័យថា ដែលទូទៅ ទាំងមូល ទាំងគ្រប់។(វចនានុក្រមសម្ដេច សង្ឃរាជជួន ណាត ទំព័រ១២២៦-១២២៧)

ឧទាហរណ៍៖ចំណោះសកលមានន័យថាចំណោះដែលទូទៅក្នុងលោក។ទាំងសកលឬសាកលពេញទូទៅ ទាំងអស់។បែបសកលបែបឬបែបបទដែលប្រើត្រូវគ្នាក្នុងលោកទាំងមូល។សាកលលោក មានន័យថាលោកទាំងមូល។

By Cambridge and Oxford dictionaries, the word “Global” means relating to the whole world.

( តាមវចនានុក្រមCambridge និងវចនានុក្រម Oxford ពាក្យថាសកលមានន័យថាដែល ទាក់ទងតទៅនឹងពិភពលោកទាំងមូល។)

សរុបមកសកល ឬសាកលមានន័យថាជាអ្វីៗដែលទូទៅដោយមានការទទួលស្គាល់ទាំងអស់គ្នាតាមតំបន់ ប្រទេសនីមួយ ៗឬ ពិភពលោកទាំងមូល។

## ៣.លក្ខណៈជាសកលនៅក្នុងតំបន់តាមរយៈរឿងទុំទាវ ៖

នៅក្នុងស្នាដៃអក្សរសិល្ប៍ជាច្រើនមិនថាអក្សរសិល្ប៍ខ្មែរ ឬអក្សរសិល្ប៍បរទេសទេគឺសុទ្ធតែ មានគោលបំណងស្វែងរកសច្ចៈយុត្តិធម៌ សេរីភាព និងសុភមង្គលឲ្យមនុស្ស។ ជាការពិតតាមរយៈការវិភាគរបស់លោក **វ៉ាន់ ឌីការុន** អំពីអក្សរសិល្ប៍បរទេស មួយចំនួន ពិសេសអក្សរសិល្ប៍របស់បារាំង។តាមរយៈការវិភាគរបស់លោកយើងអាចធ្វើការប្រៀបធៀបបានថា ទោះបីបរទេសមានអ្វី របស់យើងក៏មានហ្នឹងដែរ ជួនកាលរឿងរបស់គេបង្ហាញតែមួយជ្រុងប៉ុណ្ណោះ ដោយឡែករឿងរបស់យើងវិញក្ដោបយកគ្រប់ជ្រុងជ្រោយទាំងអស់។ បើយើងក្រលេកមើលទ្រឹស្ដីនៃអក្សរសិល្ប៍នៅដើមសតវត្សទី១៩របស់បារាំង គឺជាចលនាមួយឈានទៅរកចលនាមួយបែបទំនើប ដូចជាចលនារ៉ូម៉ង់ទិសឬចលនាអណ្ដែតអណ្ដូងនិយម។ ពួកគេបាននាំគ្នារំដោះខ្លួនចេញពីរបៀបពិចារណាបុរាណ ហើយបានជះឥទ្ធិពលទៅលើវិស័យផ្សេងៗ។គោលដៅរបស់ពួកគេសំខាន់គិតពីតម្លៃរបស់មនុស្សដែលផ្ដោតទៅលើបីចំណុចគឺ៖

ក.ស្វែងរកសុភមង្គល សេរីភាពនិងសច្ចធម៌មានន័យថាឲ្យពួកគេសម្រេចអ្វីទៅ តាមគោលដៅរបស់ពួកគេ ដោយគ្មានការបង្ខិតបង្ខំអ្វីឡើយ។

ខ.តស៊ូប្រឆាំងនិងអ្វីៗដែលធ្វើឲ្យប៉ះពាល់ដល់ការរីកចម្រើនរបស់មនុស្ស មានន័យថាបុគ្គលម្នាក់មិនត្រូវបានគេគម្រាមកំហែង ការបោកប្រាស់ យកភាពថ្កុំថ្កើងទ្រព្យសម្បត្តិមកបង្ក្រាបភាពបរិសុទ្ធភាពបរិសុទ្ធរបស់មនុស្សហើយយកអំណាចផ្ដាច់ការមករាំងស្ទះសិទ្ធិសេរីភាពរបស់មនុស្ស។ឧទាហរណ៍មនុស្សចង់ធ្វើអ្វីគឺត្រូវតែធ្វើទោះបានសម្រេចក្ដីមិនបានសម្រេចក្ដី ។

គ.ត្រូវមានឆន្ទៈគ្រប់គ្រាន់ដើម្បីជួយមនុស្សឲ្យកន្លងផុតពីបរាជ័យរបស់គេម្នាក់ៗគឺ ការប្រឆាំងបះបោរនិងតថភាពដ៏គ្រោតគ្រាតនៃពុភពលោកតែម្ដង។

អត្ថបទរឿងទុំទាវសុទ្ធតែបានបង្ហាញពីអ្វីដែលគោលការណ៍នេះបានលើកឡើង ព្រោះថាបើក្រលេកទៅមើលគោលការណ៍ទីមួយគឺរឿងបានបង្ហាញរួចទៅហើយ ដូចជា អ្នកនិពន្ធបានឲ្យតួអង្គទុំនិងទាវសុទ្ធបានទាមទារសិទ្ធិសេរីភាពក្នុងការជ្រើសរើស គូស្រករ ព្រះបាទរាមារកយុត្តិធម៌ឲ្យទុំទាវជាដើម។ ចំណែកឯគោលការណ៍បន្តបន្ទាប់ទៀត ភិក្ខុសោម ក៏បានបង្ហាញដែរតាមរយៈតួអង្គទុំទាវដដែលជម្នះគំនិតចាស់គម្រិល(នំមិនធំជាងនាឡិ) ពីម្ដាយទាវ ហ៊ានសារភាពចំពោះមុខព្រះរាជា ដោយមិនខ្លាចស្លាប់ ចេះទទួលស្គាល់ការពិត មានស្នេហាប្រកបដោយភក្ដីភាព ហ៊ានទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនមានដជាដើម។ ហេតុផលទាំងអស់នេះហើយធ្វើឲ្យយើងទាញបានថារឿងទុំទាវពិតជាមានលក្ខណៈសកលប្រាកដមែន។

## ៤.លក្ខណៈជាសកលនៅក្នុងប្រទេសកម្ពុជាតាមរយៈរឿងទុំទាវ ៖

សាកលមានន័យថាដែលទូទៅទាំងមូលទាំងគ្រប់ទាំងអស់។សកលពុំមែនប្រកាន់ជា របស់នរណាម្នាក់ឡើយ។ពិតណាស់នៅក្នុងរឿងទុំទាវ បានលើកឡើងពីលក្ខណៈសកលជាច្រើនដូចជា ប្រវត្តិសាស្ត្រ របបគ្រប់គ្រងទឹកដីខ្លែង សម្បត្តិធម្មជាតិ ជីវភាពរស់នៅនៃសង្គមខ្មែរ និងទំនៀមទម្លាប់ប្រពៃណីជាដើម។

### ក.ព្រឹត្តិការណ៍សំខាន់ៗទាក់ទងនឹងប្រវត្តិសាស្ត្រ ៖

សម័យលង្វែកគឺជាសម័យមួយដែលប្រទេសកម្ពុជាយើងមានចម្បាំងជាមួយនឹងប្រទេសជិតខាងមានសៀមជាដើម។សៀមបានឈ្លានពានប្រទេសខ្មែរជាញឹកញាប់ពិសេសពេលដែលស្ដេចខ្មែរកំពុងតែដណ្ដើមរាជគ្នា។ពេលនោះហើយដែលសៀមបានប្លន់យកក្បួនខ្នាតគម្ពីរផ្សេងៗពិសាសគឺព្រះគោដែលជាឃ្លាំងផ្ទុកក្បួនខ្នាតផ្សេងៗរបស់ខ្មែរ យកទៅស្រុកវាបាត់រហូតមកដល់សព្វថ្ងៃ។

សម័យនោះសូមរាប់ចាប់ពីស្ដេចអង្គច័ន្ទទី១មក រួចជាបន្តបន្ទាប់។

-ព្រះបាទអង្គច័ន្ទទី១ ពេលព្រះអង្គយាងមកពីប្រទេណសសៀមវិញ ព្រះអង្គបានធ្វើគតស្ដេចកនៅសំរោង រួចព្រះអង្គក៏ឡើងគ្រងរាជ្យ(១៥០៥ដល់១៥៥៧)ដោយលើករាជធានីទៅលង្វែក។

-សៀមបានចាត់ឲ្យ ពញាអុងដែលជាស្ដេចខ្មែរបានចិញ្ចឹមទុក ឲ្យចេញច្បាំងដណ្ដើមរាជដោយមានទ័ពសៀមនៅពីក្រោយ។

-ពេលនោះសៀមបានវាយលង្វែកបានជាលើកដំបូងនៅឆ្នាំ ១៥៣២។

-នៅឆ្នាំ១៥៨១ ស្ដេចសៀមព្រះចៅ នរេសួន បានបញ្ជាទ័ពយ៉ាងច្រើនមានពល ១៥០.០០០នាក់

ព្រមទាំងដំរីនិងសេះប្រមាណជាងពីរពាន់។

-ទ័ពសៀមវាយលុកដល់ខេត្ត បាត់ដំបង ពោធិសាត់ អង្គរ រលាប្អៀរ និងបរិបូរណ៍ «កំពង់ឆ្នាំង»

-ព្រះបាទជ័យជេដ្ឋាទី១ (១៥៧៦ដល់១៥៩៣) បានវាយកំចាត់សៀមវិញ។

-នៅឆ្នាំ១៥៩៣ សៀមបាននាំទ័ពមកវាយខាងកើតកំពង់ស្វាយ ទន្លេសាប ហើយទីបំផុតយកបានលង្វែក។មិនតែប៉ុណ្ណោះសៀមបានចាប់ស្តេចស្រី សុរិយោពណ៌ និងប្រជាជនប្រមាណប្រាំបួនម៉ឺននាក់ ព្រមទាំងប្រមូលក្បួនខ្នាតយកទៅស្រុកវាអស់។

ក្នុងរាជព្រះបាទរាមាជើងព្រៃ(១៥៩៤ដល់១៥៩៨)បានកេណ្ឌទ័ពទៅវាយសៀមយកបានលង្វែកនៅឆ្នាំ១៥៩៤ ដោយបានសម្លាប់មេទ័ពសៀម និងសម្លាប់ពួកពលវាប្រមាណពីរម៉ឺននាក់។

-ព្រះបាទ ពញា តន់(១៥៩៨ដល់១៥៩៩)

-ព្រះបាទ ពញា អន(១៥៩៩ដល់១៦០០)

-ព្រះបាទពញា ញោម(១៦០០ដល់១៦០២)

តាមរយៈព្រឹត្តិការណ៍បានឆ្លុះបញ្ចាំងឲ្យឃើញយ៉ាងច្បាស់ពីរបបគ្រប់គ្រងនាសម័យលង្វែកដែលប្រជាជនខ្មែរទាំងអស់ចាំទុកក្នុងចិត្តពុំអាចបំភ្លេចបានឡើយ។

**ខ.របៀបគ្រប់គ្រងរដ្ឋ៖**

អត្ថបទរឿងទុំទាវព្រះបុទមត្ថេរ ងួន សោម បានរៀបរាប់ពីរបៀបរបបនៃការគ្រប់គ្រងប្រទេសនាសម័យលង្វែក។ក្នុងពេលនោះការគ្រប់គ្រងប្រទេសមានរូបភាពជារបបសក្តិភូមិ មានន័យថាបន្ទាប់ពីស្តេចផែនដីមកគឺស្តេចត្រាញ់ រហូតមកដល់មេគ្រួសារ។

- ***អំណាចស្តេចផែនដី៖***

ការគ្រប់គ្រងរបស់ស្តេចនៅសម័យនោះ បើតាមការពិចារណាឃើញថា មានរូបរាងជារបបផ្តាច់ការ ឬ សក្តិភូមិ។ជាការពិតណាស់បានជានិយាយដូចនេះគឺសំអាងទៅលើ ការកាត់ទោសរបស់ព្រះអង្គដោយកាត់ទោសទាំងអ្នកមានកំហុស និងអ្នកគ្មានកំហុសឲ្យជាប់ទោសដូចគ្នា។ ដាក់ស្នែងអ្នកស្រុក

យកទៅឲ្យរៀនចោលគ្រឿងល្បែង ស្វះស្វែងនៅវត្តវិហារធំ។...»(ទុំទាវ.ភិក្ខុ.ទំ.៥)

- **ពិធីចូលម្លប់៖**

ប្រទេសកម្ពុជាយើងសព្វថ្ងៃពិធីនេះស្ទើរតែរលត់បាត់ទៅហើយ ប៉ុន្តែនៅមានប្រជាជនមួយចំនួនតូចដែលគាត់នៅរក្សាប្រពៃណីនេះបាន តែមិនមែនបានទាំងស្រុងនោះទេ។ ជាក់ស្តែងអ្នកស្រុកនៅភូមិសាឡាម្នាង ឃុំបឹងព្រាវ ស្រុកស្រែអំបិល ខេត្តកោះកុង ពួកគាត់បានរក្សាប្រពៃណីនេះហើយ ក្នុងគ្រួសារនីមួយៗពួកគាត់យកកូនស្រីមួយ សម្រាប់ធ្វើពិធីនេះ រយះពេលនៃការធ្វើពិធីគឺអាស្រ័យលើពេលវេលាជាក់ស្តែង(ចាប់ពីមួយខែឡើង)។ដោយឡែកនៅក្នុងរឿងទុំទាវវិញម្តាយទាវបានរៀបចំឲ្យទាវចូលម្លប់ដែរ ដោះម្បីរៀនក្បួនច្បាប់ផ្សេងៗ។

- **ពិធីស្តីដណ្តឹង៖**

ការស្តីដណ្តឹងគឺជាពិធីមួយដែលតម្រូវឲ្យចាស់ទុំឬចៅមហាខាងប្រុសចូលទៅចែចូវ មេបាខាងស្រី ដើម្បីគោរពតាមទំនៀមទម្លាប់របស់ខ្មែរយើង។ដោយឡែកនៅក្នុងរឿងទុំទាវ អរជូន ទោះបីគាត់ជាចៅហ្វាយខេត្តត្បូងឃ្មុំក៏គាត់នៅតែប្រត្តិបត្តិតាមប្រពៃណីដែលប្រជាជន ទូទៅអនុវត្តតាម។ ដូចមានឃ្លាបញ្ជាក់ថា៖

«អធិប្បាយនិយាយខាងចែចូវ ជាអ្នកនាំផ្លូវតាមដូនតា
ឲ្យទៅស្រដីខាងមេបា នាងទាវតើថាប្រការម្តេច។...» (ទុំទាវ.ភិក្ខុ.ទំ.៣៧)

- **ពិធីរៀបអាពាហ៍ពិពាហ៍៖**

ពិធីមង្គលការគឺ ជាពិធីមួយដែលប្រជាជនខ្មែរគ្រប់រូបត្រូវការជាចាំបាច់ ព្រោះវាជា ប្រពៃណីមួយតម្រូវឲ្យមនុស្សគ្រប់ស្រទាប់វណ្ណៈបំពេញជាការចាំបាច់ នោះជីវិតរស់នៅ ប្រាកដជាមានន័យហើយក៏ជាអ្នករក្សាប្រពៃណីបានល្អក្នុងសង្គម។ចំពោះរឿងទុំទាវក៏បានបង្ហាញពីពិធីនេះផងដែរដោយទុំនិងទាវត្រូវបានស្តេចរៀបចំការឲ្យអ្នកទាំងពីរបានជាប្តីប្រពន្ធ។ សមដូចឃ្លាមួយ លើក ឡើងថា៖

«ទ្រង់ព្រះតំរាស់នឹងកុង្សីយ៍ មាត្យមុខមន្ត្រីខ្ញុំរាជការ
ឲ្យរៀបប្រដាប់មង្គលការ ក្សត្រានឹងផ្សំទាវនិងឯក។...»(ទុំទាវ.ភិក្ខុ.ទំ.៦៣)

## ឃ.លក្ខណៈសកលតាមរយៈទាក់ទងទីកន្លែង៖

នៅប្រទេសកម្ពុជាមានឈ្មោះទីតាំងដែលប្រជាជនយើងបានស្គាល់ហើយថែមទាំងប្រើប្រាស់នៅទូទាំងប្រទេសដែលមានចាប់តាំងពីឈ្មោះ ឃុំ ភូមិ ស្រុក ខេត្ត ទីក្រុងនិងបឹងបួរ ជ្រោះជ្រងជ្រលងដងអូរ ទន្លេជាដើម។ ជាក់ស្តែង រឿងទុំទាវបានបង្ហាញពីទីកន្លែងទាក់ទងទៅនឹង

ខេត្តបាភ្នំ (ស្រុកបាភ្នំ)វត្តវិហារធំ ខេត្តលង្វែក ខេត្តខ្លុងក្រង ពោធិសាត់ បាត់ដំបង កំពង់ស្វាយ ទន្លេជាដើម។ ជាការពិតនៅក្នុងសៀវភៅ ភិក្ខុសោមបានបង្ហាញថា ៖

«ផ្កាថ្លែងសម្លែងដើមឈ្មោះទុំ នៅខេត្តបាភ្នំដែនដីស្រែ...(ទុំទាវ.ភិក្ខុ.ទំ.៥)

ឡប់ពីបាទីព្រៃកប្បាស អរបានស្រឡះដើរវិលវឹង

ចូលរកខេត្តស្ពាងកណ្ដាលស្ទឹង ពុំដឹងព្រួយចិត្តគិតស្រូតឆ្លង។

................................................................................................

លង់លុះដល់ដែនខេត្តត្បូងឃ្មុំ អរជូនជាធំមានចិនខ្មែរ

ដល់ពោធិជើងខាលមានអណ្ដូង ឃើញមនុស្សជ្រួលច្រូងឈរចិត្ត។...»(ទំ.៥៥.៥៦)

ង.លក្ខណៈសកលតាមរយៈទិដ្ឋភាពទំរែណងនិពន្ធ៖

➢ **វិធីតែងនិពន្ធ ៖**

តាមស្នាដៃរបស់ភិក្ខុ សោម លោកបាន សរសេរជា កំណាព្យ បទពាក្យប្រាំពីរ តាំងពីដើមរហូតដល់ចប់ ដោយប្រើប្រាស់ពាក្យបាលីសំស្ក្រឹតខ្លះៗ។ ធ្វើឲ្យអ្នកអានអ្នកស្ដាប់ជក់ចិត្តជិតអារម្មណ៍ក្នុងការសិក្សាស្វែងយល់អំពីរឿងនេះ។

- **ការផ្ដើមរឿង ៖** អ្នកនិពន្ធផ្ដើមរឿង ដោយរៀបរាប់ពីប្រវត្តិ របស់តួអង្គ ពិសេសគឺចាប់ផ្ដើមពីតួអង្គទុំតែម្ដង ដូចក្នុងកំណាព្យបានបញ្ជាក់ថា ៖

«នេះនិងថ្លា ថ្លែងដើមឈ្មោះទុំ នៅស្រុកបាភ្នំដែន ដីស្រែ
កើតកបទំនៀមមានឪម៉ែ ប៉ុន្តែហេតុត្បិតឥតសម្ដែង។ » (ទុំទាវ.ភិក្ខុ.ទំ.៥)

- **វចនវិធី ៖** នៅក្នុងរឿងនេះមានការប្រើប្រាស់ពាក្យពេចន៍ចម្រុះគ្នាដូចជា៖ ពាក្យសាមញ្ញមាន(ម៉ែ ទុំ ទាវ...) ៕ពាក្យរាជស័ព្ទមាន ( យាង ថ្វាយ បរពិតជាដើម) មិនតែប៉ុណ្ណោះមានបង្ហាញដូចជាពាក្យសង្ឃស័ព្ទ (ឆាន់ពុទ្ធដីកាង...) ពាក្យកម្ចីបារាំង (កុង្សី...)និងពាក្យកម្ចីសៀម (ផាហ៊ុម សាវ...) ពាក្យកម្ចីបាលីសំស្ក្រឹត (ឥស្សរា ក្សត្រ...)
- **រចនាវិធី ៖** អ្នកនិពន្ធបានសរសេរជាពាក្យកាព្យពាក្យប្រាំពីរ ៖

"នេះនិងផ្កាថ្លែងដើម ឈ្មោះទុំ នៅស្រុកបាភ្នំដែនដីស្រែ

កើតកបទំនៀមមាន ឪម៉ែ ប៉ុន្តែហេតុ ត្បិត ឥតសម្ដែង។" (ទុំទាវ.ភិក្ខុ.ទំ.៥)

- ***និទានវិធី៖*** អ្នកនិពន្ធបានសរសេរដោយប្រើវិធីនិទានបែបបុរសទី៣ដូចជាៈ

"ទុំមានអើហាប្រាជ្ញាផ្សេង មានទាំងសម្លេងរូបខ្ចីល្អក់

ល្អទ្រង់អង្គកាយសាយទឹកមុខ រូបទុកនេននពេជ្ររស្រេចជាប្អូន។..."(ទុំទាវ.ភិក្ខុ.ទំ.៥)

- ***សំវាទវិធី៖***

អ្នកនិពន្ធបង្កើតឲ្យតួអង្គមានការសន្ទនាឆ្លោះឆ្លងពីនេះពីនោះរហូតឈានដល់ចំណុចមួយគឺសេចក្តីស្នេហាគ្នាសមនិងឃ្លាមួយបានលើកឡើងថា ៖

"ទុំថាឱទាវស្រស់នួនល្អង នួនល្អម៉ត់ម៉ង ដូចចរណៃ

បងមកដល់យូរគួរអាល័យ ទាវថ្លៃលាក់ខ្លួនពួនដល់ណា។

ទាវឆ្លើយថាឆាប់ម្តេចថ្លៃអើយ ប្អូននេះខ្វល់ខ្វាយ ខ្លាំងខ្លោចផ្សា

ប្អូនមូរបារីចំណីស្លា ប្អូនចេញដងស្រាប្រាជ្ញាលេង។" (ទុំទាវ.ភិក្ខុ.ទំ.៨០)

- ***ឯកវាទវិធី៖*** អ្នកនិពន្ធបានឲ្យតួអង្គនិយាយឬគិតតែម្នាក់ឯងសមដូចឃ្លាមួយលើកឡើងពីទុក្ខរបស់ ទាវថា៖

"ទុក្ខប្អូនទៀតហើយទុំអើយអ្នក នៅលើដំនាក់ក៏ ភ្លេចខ្ញុំ

ឥឡូវប្អូនមកជ្រកដេកយំ ក្រាលក្រំដំបៅក្តៅឪរ៉ា" ។ (ទុំទាវ.ភិក្ខុ.ទំ.៦១)

- **បដិវិធី ៖** លោកភិក្ខុសោមបានបង្កើតឲ្យទាវនិងម្តាយមានគំនិតផ្ទុយគ្នា (ទាវទុក្ខធំ ម្តាយទាវសប្បាយ ចិត្ត)នេះជាសញ្ញាពីរផ្ទុយគ្នារវាងម្តាយ និងកូន។ដូចជាទុក្ខរបស់ទាវ៖

"បងមិនអាណិតចិត្តប្អូនផង ទុក្ខធ្ងន់កន្លងពុំមានស្បើយ

រូបអូនក្សិណក្ស័យទេបងអើយ ទុក្ខអើយទោម្នេញពេញជាថ្មី។"(ទុំទាវ.ភិក្ខុ.ទំ.៥៧)

ចំណែកនេះជាការសប្បាយរបស់ម្តាយទាវ៖

" ម្តាយទាវជិះទូកទៅជាមួយ ប្រុសស្រីរង្វួយមិនដឹងការណ៍

គិតស្មានទាវស្ម័គ្រនិងក្សត្រា អរឥតឧបមានាំទាវទៅ។" (ទុំទាវ.ភិក្ខុ.ទំ.៥៧)

- ***ពណ៌នាវិធី៖*** អ្នកនិពន្ធរៀបរាប់ពីសកម្មភាពតួអង្គនិងធម្មជាតិនានាតាមដំណើររឿងតែម្តង។ដូចមានឃ្លាបញ្ជាក់ខាងក្រោមស្រាប់ ៖

"នាងនៅភិល្បៀងបញ្ចៀងអោយ ថាចាំខែក្រោយមើលពពក

សាត់ពីទិសឥន្ទ្រសានជ្រក ពពកសមគ្នាមកទាវស្រី។..."(ទុំទាវ.ភិក្ខុ.ទំ.២១)

- **ឧបមាណវិធី៖** អ្នកនិពន្ធបង្កើតឲ្យមានការប្រៀបធៀបអ្វីមួយទៅនឹងអ្វីមួយផ្សេងទៀត ដូចជា:

"ទាវថាខ្លួនប្អូនដូចព្រឹក្សា អ្នកដូចសារិកាទុំសព្វថ្ងៃ

ចតជាទ្រនំទំអាល័យ ហើយ ហើរច្រៀងច្រៃទៅទីទៃ។

ទុំថាខ្លួនបង ប្រៀបដូចខ្លា ខ្លួនកែវកន្និដ្ឋាប្រៀបដូចព្រៃ

ធម្មតាសត្វខ្លាមិនវិលវៃ ចៀស ចេញចោលព្រៃណាថ្លៃបង"។(ទុំទាវ.ភិក្ខុ.ទំ.៤៣)

- **រូបារម្មណ៍វិធី៖** ជារូបារម្មណ៍ផ្សេងៗទាក់ទងទៅនឹងឥន្ទ្រីយ៍ទាំងប្រាំរបស់មនុស្សរួមមាន៖
  - **ចក្ខុរូបារម្មណ៍** ៖អ្នកនិពន្ធបានបង្កើតឲ្យមានអារម្មណ៍ទាក់ទងទៅនិងភ្នែក៖

"រូបនេនស្តាប់ជាក់ភ្ញាក់ព្រឺតព្រឹង ភ្នែកគន់សម្លឹងទៅមាត់ទ្វារ

យល់ទាវឈរស្ងួបដើរអោ ស្ទុះស្ទាវចូលក្នុងស្លុងចេញក្រៅ។(ទុំទាវ.ភិក្ខុ.ទំ.១១)

  - **ឃានរូបារម្មណ៍៖** អ្នកនិពន្ធបង្កើតអារម្មណ៍ទាក់ទងនិងក្លិនច្រមុះដូចជា:

"ទឹកអប់ត្រឡប់ផ្ទុំគន្ធរស សាប៊ូជូតដុះជ្រះសន្លាង

ក្រអូបសាប៊ូក្លិនដោយយ៉ាង ដោយយល់សំណាងសាមណេរនេន។"(ទុំទាវ.ភិក្ខុ.ទំ.១១)

  - **កាយរូបារម្មណ៍៖** ទាក់ទងនិងរូបរាង្គកាយដូចជា ៖

"ថ្លែងពីទាវទុក្ខពុំសុខសោះ នឹកឡើងស្រណោះទុំក្រោយនូវ

យល់យូស្ងប់ស្ងាត់បានស្ទុះក្តៅ ព្រះពាយផាតត្រូវ រហើយប្រាណ។"(ទុំទាវ.ភិក្ខុ.ទំ.៥៩)

  - **កាមរូបារម្មណ៍៖** ទាក់ទងផ្លូវអារម្មណ៍ផ្សេងៗ(មនោសញ្ចេតនា)

"ទាវស្រួលទទួលព្រមចូលជិត ទុំសោតស្នេហ៍ស្និទ្ធថើបភ័ក្ត្រា

តាំងពីបាក់នស្បថប្រាកដថា ខ្ទាក់ស្លាប្តូរគ្នារួចទាវឆ្លើយ។"( ទំព័រ ៤៤ )

- **នុលោមវិធី៖** ជាការអនុម័តរបស់ នរណាម្នាក់

ជួបជុំបតីមន្ត្រីធំ ចតុស្តម្ភ មូលមកជួយរវល់

ផ្សំផ្គុំទុំទាវថ្លៃនិមល ទសពលទ្រង់ក្សាន្តមានមេត្តា។"( ទំព័រ ៦៤ )

- *ការបញ្ចប់រឿង៖*

ក្នុងរឿងទុំទាវអ្នកនិពន្ធភិក្ខុសោមលោកបានបញ្ចប់រឿងដោយក្តីអស់សង្ឃឹមព្រោះតួអង្គទាំងពីរស្លាប់គឺទុំទាវព្រមទាំងបន្សល់ទុកនូវក្តីឈឺចាប់ដល់ពួកអ្នកស្រុកត្បូងដែលជាប់ឈ្មោះជាពួកអ្នកងារ។

*«ហ៊ានបែកដុំតចោលបន្ទូលអញ ទោសវាចង់ចាញ់អាដួនកូន*

*ធ្វើទុក្ខធ្វើទោសឲ្យអស់សូន្យ សណ្តានបងប្អូនបញ្ចូលងារ»* (ទំព័រ ៩១)

ជារួមយើងយល់ញថាការបកស្រាយនៅក្នុងអត្ថរូបខាងលើនេះ ពិតជាមានលក្ខណៈសកលមែន ព្រោះថារឿងទុំទាវវាបង្ហាញអំពីជីវិតពិតជាក់ស្តែងនៅក្នុងសង្គម។

**ច.ទិដ្ឋភាពវិភាគអត្ថរស ៖**

- ***ភាពរស:*** ជាតម្លៃដែលអាចចេញពី សម្ផស្ស កាព្យ សូរស័ព្ទ សំលេងកាព្យ ពាក្យពេចន៍ពិរោះ ចួនរណ្តំណៃងណង គួរឲ្យជក់ចិត្តជិតអារម្មណ៍។

*"លង់លុះគំរប់ចប់ជួលជា វេលាខែបុស្សព្យុះខ្យល់ផាត់*

*រហើយត្រជាក់ភ្ញាក់ព្រឺប្រាត់ ផាយផាត់ពពកមកដេរដាស។»* (ទំព័រ ១៩)

- ***ប្រលោមរស ៖*** មានការផ្សងព្រេងអណ្តែតអណ្តូងស្នេហាជាក់ស្តែងក្នុងរឿងទុំទាវក្នុងពេលព្រាត់គ្នាចូលព្រៃជិះសេះដើរកាត់វាល ប្រលងភ្នំព្ន សូរស័ព្ទយាសយំ។

*"រួចដើរកាត់ព្រៃខេត្តត្បូងឃ្មុំ ស្តាប់សត្វយាសយំទុំអាស្រ័យ*

*ឈ្មោលញីទាំងពីរយំច្រៀងច្រៃ ស្រមៃដូចទាវនៅនៃបនិត្យ។"* (ទំព័រ ៤៨)

- ***ទារុណរស ៖*** ជាតម្លៃបង្ហាញពីទារុណកម្មហើយមានសភាពព្រៃផ្សៃ(ដូចជាការសម្លាប់ទុំ)

*"ទុក្ខម្នោទោម្នេញក្នាញ់ឆុរឆាវ កន្ត្រាក់បានដាវស្ទុះចូលជុំ*

*ចូលចាប់ចាក់កាប់ឥតជិនុំ ចង់ទុំក្រញឹតស្លឹតស្លាបសេក។*

  - **ទារុណកម្មផ្លូវកាយ ៖** អ្នកនិពន្ធបានបង្ហាញតាមរយៈតួអង្គទុំដោយការធ្វើទណ្ឌកម្មទុំពីសំណាក់អរ ជូននិងបក្សពួក។ដូចជាក្នុងកំណាព្យបញ្ជាក់ថា៖

*"គេចោមចាប់ទុំចងនឹងខ្សែ ចាក់មុខបង្អែតឥតគិតឡាន*

គិតឆ្ងាតប្រណីដល់គិចគ្មាន ធ្វើទោសបំពានឥតមានខុស។
ទុំឈឺដម្ងឹងងឹតមុខ ឈាមចុកធ្លុះស្បៀតក្តៅដូចស្រុស
ដូចស្រែកទឹកពេកណាធ្លាយពោះ សាប់សុសធ្លុះសាច់ដាច់សរសៃ។»(ទំព័រ ៨៣)

- **ទារុណកម្មផ្លូវចិត្ត៖** អ្នកនិពន្ធបានបង្ហាញតាមរយៈតួអង្គទាវដោយបង្ខំទាវឲ្យរៀបការ ជាមួយម៉ឺន ងួន ដែលខ្លួនមិនបានស្រឡាញ់។ក្នុងកំណាព្យបង្ហាញថា៖

"នៃទាវទំនៀមព្រេងប្រៀប ស្រាប់ ថាកូនមិនស្លាប់ចចេសរឹង
លោក យកទាញមករកសន្ទឹង របឹងរបាញ់សាញចណ្ហាល។
មិនដែលសោះឡើយទាវ អើយនំ ច្រឡើសបើសចំម្តេចជាងនាឡិ។(ទំព័រទី៣៩)

- **កម្សត់រស៖**
អ្នកនិពន្ធតម្រូវតួអង្គឲ្យទុំទាវព្រាត់ប្រាស់ពិសេសពេលដែលនាងទាវឃើញគេធ្វើបាបប្តីទាំងភ្នែកស្រស់ ធ្វើឲ្យមានការសង្វេគកើតមានឡើង។ បញ្ជាក់ក្នុងកំណាព្យស្រាប់៖

"ទាវឮគេថាចោមចាប់ប្តី ក្តួលក្តៅទាវស្រីនឹកសង្វេក
ទុំថាទាវអើយសមបងបែក បងលាទៅដេកលើផែនដី។(ទំព័រទី៨៣)
ប្អូនស្តាយប្រុសថ្លៃអាល័យពេក ស្តាយណាស់នឹងដេកឆ្មេចមិនលក់
ពេលស៊ីប្អូនអត់បត់តែទុក្ខ ទុំចុកចោតឆុងផុងដល់ក្ស័យ។
ទុំអើយប្រុសធ្លាប់រាប់អានខ្ញុំ មិនដែលវាយដំហោតុងអាល័យ
ប្អូន ចាំមើលផ្លូវរាល់ខែថ្ងៃ ស្តាយណាស់ប្រុសថ្លៃសង្ស័យមក។(ទំព័រទី៨៤)

- **វីររស៖** ភាពអង់អាចក្លាហានរបស់ទុំ(ជាវីរជន) ទាវ(ជាវីរនារី) សកម្មភាពគេទាំងពីរនាក់ធ្វើដើម្បីសិទ្ធិសេរីភាពដល់ ជនទូទៅក្នុងការជ្រើសរើសគូស្រករ។ ទុំមិនខ្លាចស្លាប់ទោះបីនៅចំពោះមុខព្រះរាជាទុំនៅតែសារភាព ដូចមានឃ្លាបញ្ជាក់៖

"កាលនោះទុំសោតខ្លាចបារមី ផ្សៀង ស្តាប់ដាក់ខ្មីលើកករផ្គង
ទុំទូលក្សត្រាដោយស្មោះត្រង់ សូមទានព្រះអង្គប្រោសប្រណី។
ករុណាសម្លាប់តាមទោសធំ ទុករស់ជាខ្ញុំព្រះបារមី
ទូលបង្គំជាខ្ញុំមិនលាក់ ថ្មីឯនាងទាវស្រីសង្ហាភាពិត។(ទំព័រទី៦៣)

- **នាដ្យរស ៖** តម្លៃដែលលេចចេញមកពីការកំសត់នៅក្នុងរឿងវិបត្តិ ទំនាស់ ប្រឆាំងគ្នា តួអង្គបក្ខដិបក្ខទុំទាវនិងម្ដាយទាវ អរជូននិងព្រះរាមាក្នុងរយៈពេលតំបូង នៃរឿង មុនការបោកប្រាស់ទាវ យកមករៀបការ។វិបត្តិទំនាស់រវាងមនុស្សធម្មតាមានចាញ់មានឈ្នះ។

  "អញប្រាប់ឲ្យមានបានថ្កុំថ្កើង ហ៊ានហួសចចើងស្ដីគ្មានត្រូវ
  ស្រឡាញ់អាទុំគ្មានម៉ែឪ គ្មានគិតអាស្រូវកាសខ្មាសគេ។"(ទំព័រ ៦៨)

- **សមរស ៖** អ្នកនិពន្ធធ្វើឲ្យចិត្តគំនិត អ្នកអានពេញចិត្ត ចាប់ចិត្ត ក្នុងចិត្តទៅជា សប្បាយរីករាយជាដើមដូចជាការរៀបរាប់ពីតួអង្គទុំទាវល្អបណ្ដាច់។

  "ទុំមានវោហាប្រាជ្ញាផ្ទេរផ្ទង់ៗ មានទាំងសម្លេងរូបខ្ពីល្អក់
  ល្អទ្រង់អង្គកាយសាយទឹកមុខ រូចទុកនេនពេជ្ររស្រេចជាប្អូន។

  ស្ដេចទ្រង់បែរបៀងទៀងទតដាក់ យល់ទាវលក្ខ័សមកាយា
  ត្រូវព្រះហឫទ័យមានឪង្ការ ថ្លែងថារូបទាវគួរអាល័យ។"(ទំព័រ ៦១)

- **លោកិយសច្ចៈ ឬគថរស ៖** អ្នកនិពន្ធ តែងយកបញ្ហាមនុស្សឬរឿងមនុស្សមកចោទនិងដោះស្រាយ ព្រមទាំងបានរៀបរាប់ពីស្ថានភាពជាក់ស្ដែងក្នុងសង្គមទៀតផង។ដូចជា៖

  _ទីកន្លែង: ត្បូងឃ្មុំ បាភ្នំ លង្វែក...

  _តួអង្គ: ព្រះបាទរាមា អរ ជូន...

  _ពេលវេលា: សម័យលង្វែក

  _ប្រពៃណី: នំមិនធំជាងនាឡិ ពិធីស្ដីដណ្ដឹង រៀបការ...។

  "ទ្រង់មានចិន្ដាកាលណាឈប់ ស្ដេចត្រាស់បង្គាប់ជៀងដាក់ស្ដែង
  ឲ្យហៅកុម្ភវីយ៍បតីតែង បន្ទូលចាត់ចែងរើសមហេសី"។(ទំព័រ ៥៤)

- **សង្គមរស ៖** ឲ្យតម្លៃទៅលើសង្គមដូចជាក្នុងរឿងទុំទាវបានលាតត្រដាងពីជីវភាពរស់នៅជាក់ស្ដែងរបស់មនុស្សក្នុងសម័យមួយដែលទាក់ទងនឹងបញ្ហាវិបត្តិទំនាស់ការរំលោភយោបល់គ្នាក្នុងគ្រួសារ ភូមិ ខេត្ត ខណ្ឌ នគរ។

  "ថាបើម៉ែព្រមល្អមនឹងគេ កូនម៉ែទំនេរមានប្រុសស្រី
  លើកឲ្យគេទៅទោះពីរបី តាមម៉ែមេត្រីឲ្យថ្មីខ្ញុំ"។(ទំព័រ ៣៩)

- **ទស្សនីយរស ៖** ករីរៀបរាប់ទេសភាព ធម្មជាតិយ៉ាងពិរោះជាពិសេស រៀបរាប់តាម ដងទន្លេមេគង្គ ទីក្រុង ត្បូងឃ្មុំក្នុងនោះព្រះបាទរាមាយាងមកជិនុំជិះអរជូននិងក្រុមបក្សពួក។ដូចជា៖

"សករាទិឌីណាផ្កាកំភ្លឹកព្រៃ ស្ងប់ស្ងួតព្រះទ័យទសពល
ទសពិធមានរិទ្ធីឥតទប់ទល់ ទ្រង់ខ្វល់ឆ្ងល់ឆ្ងាយស្ដាយ អនេក។
សករាឌីណាផ្កាចំប៉ី ចំពប់ដោយ ក្ដីទ្រង់សង្វេគ
សង្វាតយាងដល់កម្មអ៊ីបែក សង្វេគរាល់ខ្លួនបំនួននៅ" ។( ទំព័រ ១០២ )

- *កុសលរស* ៖ ក្នុងនេះអ្នកមានគំនិតផ្សេងក្នុងការអប់រំដល់កុលបុត្រ កុលធីតាខ្មែរ ដើម្បីកុំឲ្យមានការខុសឆ្គងដូចតួអង្គនៅក្នុងរឿងទៀត ដូចជា:

អប់រំអ្នកសិក្សាឲ្យមើលពីតម្លៃនៃជីវិតមនុស្សធំជាងទ្រព្យសម្បត្តិ បុណ្យសក្ដិ មាសប្រាក់ អំណាច ហើយបង្ហាញឲ្យឃើញពីរបបសក្ដិភូមិ ដែល ប្រកាន់យករបបផ្ដាច់ការគ្មានយុត្តិធម៌ ព្រមទាំងអប់រំយុវជនកុំឲ្យយកស្នេហាជាធំ ព្រោះនាំឲ្យអន្តរាយដល់ជីវិត។សមដូចឃ្លាថា៖

«កុំយកគំរាប់គាត់ពេជ្រទុំ នៅទីត្បូងឃ្មុំអ្នកលេងផុង
លេងភព្វស្រីទាវលើអមានទ្រង់ លិចលង់លុះបានប្រាណមរណា។»( ទំព័រទី៨០)

ឆ្លងតាមការបកស្រាយអត្ថរសខាងលើរួចមកធ្វើឲ្យយើងសន្និដ្ឋានបានថា រឿងទុំទាវពិតប្រាកដណាស់ដែលមានលក្ខណៈរួមហើយសកលទៀត ព្រោះខ្លឹមសារនៃរឿងសុទ្ធតែលើកឡើងពីតថភាពជាក់ស្ដែងនៅក្នុងសង្គមពិតៗ។

ឆ.លក្ខណៈសកលតាមរយៈសកម្មភាពសិល្បៈផ្សេងៗ ៖

រឿងទុំទាវជារឿងមួយដែលមានការចាប់អារម្មណ៍ពីមហាជនយ៉ាងខ្លាំង ។រឿងនេះពិតជាមានការពេញនិយមយ៉ាងខ្លាំងពីគ្រប់មជ្ឈដ្ឋានរហូតដល់អ្នកសិល្បៈមួយចំនួននាំគ្នាយកសាច់រឿងមកសម្ដែងតាមប្រភេទសិល្បៈនីមួយៗ ហើយការសម្ដែងនោះមានដូចជា ភាពយន្ត ល្ខោន យីកេ កម្លែង និង ចម្រៀងកាយវិការជាដើម។

- *ការសម្ដែងភាពយន្ត* ៖
រឿងទុំទាវត្រូវបានផលិតកម្មប្រចាំទូរទស្សន៍មួយចំនួនបានចំណាយលុយជា ច្រើនសម្រាប់ថត និងសម្រាប់ចាក់ផ្សាយ។ជាការពិតដូចជាទូរទស្សន៍ PNN បានចាក់ផ្សាយកន្លងមកហើយ ដើម្បីទុកឲ្យអ្នកសិក្សា ពិសេសប្អូនៗថ្នាក់១០ បានចងចាំនិងយល់ច្បាស់អំពីអត្ថន័យ នៃរឿងនេះ។
- *ការសម្ដែងល្ខោនឬយីកេ* ៖
ចាស់ៗគាត់តែងតែចូលចិត្តល្ខោនឬយីកេណាស់ពិសេសគឺរឿងដែល ទាក់ទង និងជីវភាពប្រចាំថ្ងៃរបស់គាត់។នៅពេលមានបុណ្យទានដែលជួលល្ខោនឬយីកេពួកគាត់តែងសំណូមពរ

ឲ្យក្រុមសិល្បៈទាំងនោះលេងរឿងទុំទាវ។នេះបញ្ជាក់ថារឿងនេះពិតជាមានការនិយមពីមហាជនមែន។

- ***ការសម្តែងតាមរយៈក្រុមកំប្លែងផ្សេងៗ៖***
  រឿងទុំទាវបានបង្កប់នូវអត្ថន័យជាច្រើនសម្រាប់អប់រំមនុស្សឲ្យពិតម្លៃរបស់មនុស្ស។ខ្លឹមសាររឿងទាំងមូល បានអប់រំគ្រប់វណ្ណៈទាំងអស់។ ហេតុនេះទើបក្រុមកំប្លែងបានដក ស្រង់វគ្គខ្លីៗដើម្បីកំសាន្តក្នុងន័យអប់រំ។ដូចជាក្រុមពូកុយ នាយក្រឹម ពៃកមី ជាដើម។
- ***ការសម្តែងតាមរយៈចម្រៀងកាយវិការ៖***
  ចម្រៀងកើតមកអំពីការច្រៀងរបស់មនុស្សហើយកាយវិការក៏ជាអំពើរបស់មនុស្ស។មានន័យថាជាការធ្វើសកម្មឲ្យស៊ីរវាងការច្រៀងនិងការធ្វើកាយវិការ។ប៉ុន្មានឆ្នាំចុងក្រោយនេះការរីកដុះដាលនៃចម្រៀងកាយវិការបានកើនឡើងលំដាប់តាមរយៈការយកសាច់រឿងផ្សេងៗមកសម្តែងក្នុងនោះក៏មានរឿងទុំទាវផងដែរ។ចម្រៀងប្រភេទនេះមិនត្រឹមតែចាក់តាមទូរទស្សន៍នោះទេគឺរហូតដល់អ្នកចាក់ធុងបាសតាមការឬបុណ្យនិយមចូលចិត្តទៀតផង។នេះបញ្ជាក់ថាការពេញចិត្តចូលចិត្តរបស់មនុស្សទូទៅបែបហ្នឹងហើយទើបគេចាត់ទុកជាលក្ខណៈសកល ។

សរុបមកការសម្តែងសិល្បៈទោះបីមានរូបភាពផ្សេងៗគ្នាក៏ដោយក៏ការសម្តែងដើម្បី សម្រេចបំណងពីរគឺសម្រាប់កម្សាន្តកែអផ្សុកនិងការអប់រំ។បំណងទាំងពីរនេះហើយទើប ធ្វើឲ្យមនុស្សទូទៅនិយមនិងចូលចិត្ត ។ ដូចជារឿងទុំទាវដូច្នេះដែរ គឺក្រុមអ្នក សិល្បៈយកទៅ សម្តែងតាមទម្រង់ផ្សេងៗ ជារឿងអស្ចារ្យនៅក្នុងលោក។

## ៥.សេចក្តីសន្និដ្ឋានៈ

ក្រោយពីបានសិក្សាលក្ខណៈសកលនៅក្នុងរឿងទុំទាវរួចមកយើងឃើញថាស្នាដៃនេះតំណាងឲ្យអរិយធម៌ជាតិខ្មែរទាំងមូល។ ព្រោះថារឿងនេះបានបង្ហាញគ្រប់សកម្មភាព គ្រប់ស្រទាប់ វណ្ណៈ ទាំងអស់គឺចាប់ ពីរាស្ត្រតូចតាចរហូតដល់ព្រះមហាក្សត្រ។រីឯមួយទៀតគឺបង្ហាញពីទំនៀមទម្លាប់ប្រពៃណី ស្នេហា របបគ្រប់គ្រង សេដ្ឋកិច្ចសង្គមធនធានធម្មជាតិនិយាយឲ្យចំគឺជុំវិញបញ្ហារបស់មនុស្ស ដែលកើតមាននៅក្នុងសង្គមតែម្តង។ម្យ៉ាងទៀតវិញអត្ថបទអក្សរសិល្ប៍មួយរឿងនេះ(រឿងទុំទាវ)ជារឿងមួយមិនចាញ់បរទេសឡើយ ដោយហេតុថារឿងរបស់បរទេសមួយចំនួនមិនបានបង្ហាញគ្រប់ជ្រុងជ្រោយដូចរឿងទុំទាវនេះទេ គឺគ្រាន់តែបង្ហាញលម្អិតនៅផ្នែកណាមួយប៉ុណ្ណោះដូចជា បញ្ហាស្នេហា ឬជាការវាយប្រហារតាមរយៈអត្ថបទរឿងអក្សរសិល្ប៍របស់ក្រុមកវីនិពន្ធអ្នកមាននិងអ្នកក្រ (ចលនារ៉ូម៉ង់ទីសរបស់បារាំង)។

ជាការពិតណាស់នូវរាល់បញ្ហាលក្ខណៈសាកលដែលបានកប់ក្នុងស្នាដៃអក្សរសិល្ប៍ជាតិយើងដែលមានកន្លងមកយូរមកហើយ គ្រាន់តែយើងមិនបានចាប់អារម្មណ៍តែប៉ុណ្ណោះ។ ព្រោះថាយើង

អាន ឃើញមើល ឬទស្សនានោះដោយពុំបានពិចារណាឬយកចិត្តទុកដាក់ កត្តានេះហើយធ្វើឲ្យអ្នកទាំង ឡាយយល់ថាមិនមានអ្វីជាលក្ខណៈរួម ឬសាកលនោះ ។ ម្យ៉ាងទៀតដោយសារតែអក្សរសិល្ប៍ខ្មែរយើងមានការទទួលឥទ្ធិពលពីព្រាហ្មណ៍សាសនា និង ព្រហ្មញ្ញសាសនាផង។ ដោយឡែកភិក្ខុសោម បានញែកដាច់ស្រឡះចេញពីគ្នាគឺមិន ឲ្យមានភាព ច្របូកច្របល់ឡើយ ហើយលោកបានពន្លេចឲ្យ ឃើញពីតម្លៃរបស់មនុស្ស តាមរយៈការអប់រំមនុស្ស ឲ្យ ចេះស្រឡាញ់ជីវិត កុំមានចិត្តលោភលន់ ត្រូវមានសច្ចធម៌នៅក្នុងខ្លួន ចេះសម្បទានឲ្យគ្នាទៅវិញ ទៅមកដោយមិនរើសអើង មិនប្រកាន់បក្សពួកជាដើម។

ការយល់ឃើញបែបនេះ ក៏ដោយសារការសិក្សាឲ្យបានស៊ីជម្រៅហើយម៉ត់ចត់ ។ ការស្គាល់អក្សរសិល្ប៍ដែលមានលក្ខណៈសកល ជាផ្នែកមួយនៃការស្គាល់ អរិយធម៌របស់ខ្មែរ ស្គាល់បញ្ហារបស់ខ្មែរ ដើម្បីមានភាពងាយស្រួលក្នុងការប្រៀបធៀបជាមួយនិងបរទាស។ ការយល់ លក្ខណៈសកលនៅក្នុងអក្សរសិល្ប៍ជាផ្នែកមួយនៃការកសាងមាតុភូមិ ព្រោះថាវាជាត្រីវិស័យមួយ សម្រាប់បំភ្លឺជាទុនសម្រាប់កសាងជាតិហើយ ក៏ជាវប្បធម៌មួយ ដែលពលរដ្ឋគ្រប់រូបត្រូវដឹង ។

តាមការសិក្សា ការសង្កេតពិនិត្យ វិភាគឲ្យបានស៊ីជម្រៅ ទើបដឹងថា បុព្វបុរសយើងពិតជាមាន ទេពកោសល្យខ្ពស់ក្នុងការតែងនិពន្ធ ដូចជា ភិក្ខុ សោម ថ្វីត្បិតតែជាអត្ថបទកំណាព្យ តែមានមនោសញ្ចេតនា មាន ភាពចួន ផ្ទួន រណ្ដំរណែងណងហាក់ដូចជាអានអត្ថបទរាយដូច្នេះដែរ ។

តាមរយៈកិច្ចការធ្វើឲ្យខ្ញុំដឹងយ៉ាងច្បាស់ពី ទេពកោសល្យរបស់បុព្វបុរសខ្មែរយើង ដែលបានបង្កើតស្នាដៃនេះឡើងក្នុងការរួមចំណែកលើកស្ទួយ ថែរក្សាការពារ វប្បធម៌ព្រលឹងជាតិខ្មែរឲ្យកាន់តែរុងរឿងរីកចម្រើនថ្លៃថ្លា តទៅមុខទៀត៕